**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៦០៨ សហវ.ប្រក

# ប្រកាស
# ស្តីពី
# អាជីវកម្មធានារ៉ាប់រងអាយុជីវិត

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ ០៤/អនក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០០/០២ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យលេខ ១០៦ អនក្រ ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០១ ណែនាំអនុវត្តច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងការកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញប្រកាសលេខ ៥៨៤ សហវ ប្រក ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពីការកែសម្រួលការរៀបចំ និង ការប្រព្រឹត្តទៅនៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## ស ម្រេ ច

## ជំពូក ១

## បទប្បញ្ញត្តិទូទៅ

### ប្រការ ១ : និយមន័យ

ពាក្យសំព្ទ និង ឃ្លាទាំងឡាយដែលបានប្រើប្រាស់នៅក្នុងប្រកាសនេះ មានអត្ថន័យ និង ខ្លឹមសារដូចបញ្ជាក់ខាងក្រោម លើកលែងតែមានខ្លឹមសារផ្សេង ដែលបញ្ជាក់ច្បាស់ទៅតាមបរិបទនៃអត្ថបទផ្ទាល់ ÷

- " ប្រកាស " សំដៅដល់ប្រកាសស្តីពីការធានារ៉ាប់រងអាយុជីវិត ។
- " ច្បាប់ " សំដៅដល់ច្បាប់ស្តីពីការធានារ៉ាប់រង នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០០/០២ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០ ។
- " អនុក្រឹត្យស្តីពីការធានារ៉ាប់រង " សំដៅដល់អនុក្រឹត្យលេខ ១០៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០១ ស្តីពីការធានារ៉ាប់រង ។
- " ការធានារ៉ាប់រងអាយុជីវិត " សំដៅទៅលើកិច្ចសន្យាពាណិជ្ជកម្ម ដែលអ្នកត្រូវបានធានារ៉ាប់រងត្រូវបង់បុព្វលាភធានារ៉ាប់រង ទៅឱ្យក្រុមហ៊ុនធានារ៉ាប់រង ហើយក្រុមហ៊ុនធានារ៉ាប់រងត្រូវធ្វើសំណងលុសនកម្ម នៅពេលដែលអ្នកត្រូវបានធានារ៉ាប់រង ឬបុគ្គលដែលជាកម្មវត្ថុនៃការធានារ៉ាប់រង ស្លាប់ របួស ពិការ មានជំងឺ ឬក៏នៅពេលដែលកិច្ចសន្យាធានា-រ៉ាប់រងនោះ ឈានដល់កាលកំណត់ណាមួយ ដែលភាគីទាំងពីរបានព្រមព្រៀងគ្នា ដូចដែលបានបញ្ជាក់នៅក្នុងកិច្ចសន្យាធានារ៉ាប់រង ។
- " ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត " សំដៅលើនីតិបុគ្គលប្រតិស្រុតិ ដែលប្រតិបត្តិការអាជីវកម្មលក់បណ្ណសន្យារ៉ាប់រង ដោយអនុលោមទៅតាមច្បាប់ និង បទប្បញ្ញត្តិស្តីពីការធានារ៉ាប់រង ។

- " អ្នកត្រូវបានធានារ៉ាប់រង " សំដៅទៅលើបុគ្គលទាំងឡាយ ដែលបានចុះកិច្ចសន្យាទិញធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រង ហើយស្ថិតនៅក្រោមកាតព្វកិច្ចបង់ប្រាក់ថ្លៃទិញធានារ៉ាប់រងតាមកិច្ចសន្យា ។
- " បុគ្គលដែលជាកម្មវត្ថុនៃការធានា " សំដៅលើបុគ្គលទាំងឡាយណាដែលស្លាប់ របួសលើរាងកាយ ពិការ ឬមានជំងឺ ដែលជាកម្មវត្ថុនៃកិច្ចសន្យាធានារ៉ាប់រងអាយុជីវិត ។

**ប្រការ ២ : វិសាលភាព**

ប្រកាសនេះមានវិសាលភាពអនុវត្តលើគ្រប់សកម្មភាពធានារ៉ាប់រងអាយុជីវិត ដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមទៅតាមច្បាប់ស្តីពីការធានារ៉ាប់រង និងអនុក្រឹត្យស្តីពីការធានារ៉ាប់រងជាធរមាន ។

## ជំពូក ២
## ផលិតផល និង ប្រតិបត្តិការ

**ប្រការ ៣ : កម្មវត្ថុនៃការធានារ៉ាប់រងអាយុជីវិត**

អ្នកចុះកិច្ចសន្យាធានារ៉ាប់រងអាយុជីវិត អាចទិញធានារ៉ាប់រងអាយុជីវិតនេះ សំរាប់បុគ្គលដូចខាងក្រោម ÷

១- បុគ្គលខ្លួនគាត់ផ្ទាល់ ។

២- ប្រពន្ធ ឬ ប្តី កូន ម្តាយ និង ឪពុក ។

៣- បងប្អូន ប្រុស-ស្រី ឬ សាច់ញាតិដទៃទៀត ដែលជាជនស្ថិតនៅក្រោមបន្ទុករបស់អ្នកទិញធានារ៉ាប់រង ។

៤- កូនបំណុល ដោយក្នុងករណីនេះ អ្នកត្រូវបានធានារ៉ាប់រង គឺជាម្ចាស់នៃបំណុលដែលបានផ្តល់កម្ចីចំពោះកូនបំណុលនេះ ក្នុងគោលបំណងការពារទ្រព្យសកម្មរបស់ខ្លួនជាម្ចាស់បំណុល នៅពេលដែលកូនបំណុលបាត់បង់នីតិសម្បទា ឬ សមត្ថភាព ហើយករណីនេះ ផលធានារ៉ាប់រងអតិបរមា ត្រូវកំណត់ត្រឹមចំនួនទឹកប្រាក់នៃបំណុលប៉ុណ្ណោះ ។

## ប្រការ ៤ : ការអនុម័តលើផលិតផល

ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ត្រូវសុំការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជាមុនសិន មុននឹងលក់ប័ណ្ណសន្យារ៉ាប់រងលើផលិតផលថ្មី ។ លក្ខខណ្ឌពិស្តារនៃការអនុញ្ញាតនេះនឹងត្រូវកំណត់ឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ប្រការ ៥ : សិទ្ធិ និង កាតព្វកិច្ចរបស់អ្នកទិញធានារ៉ាប់រង

អ្នកទិញធានារ៉ាប់រងមានសិទ្ធិ ៖

១- ជ្រើសរើសអ្នកផ្តល់សេវាធានារ៉ាប់រងអាយុជីវិតណាមួយ (ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ភ្នាក់ងារធានារ៉ាប់រង ឬ ជើងសាធានារ៉ាប់រងអាយុជីវិត) ដែលកំពុងប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីទិញធានារ៉ាប់រងអាយុជីវិត ។

២- សាកសួរអ្នកផ្តល់សេវាធានារ៉ាប់រងអាយុជីវិត ដើម្បីបកស្រាយលក្ខខណ្ឌ និង រយៈពេលធានារ៉ាប់រង និង ផ្តល់វិញ្ញាបនបត្រធានារ៉ាប់រង ឬ ក៏ឯកសារពាក់ព័ន្ធផ្សេងៗ ។

៣- លុបចោលជាឯកតោភាគីនូវកិច្ចសន្យាធានារ៉ាប់រងអាយុជីវិត និងទទួលសំណងសម្រាប់ការខាតបង់ នៅពេលដែលអ្នកផ្តល់សេវាធានារ៉ាប់រងអាយុជីវិត មានចេតនាផ្តល់ព័ត៌មានមិនពិត ដើម្បីធានាលើកិច្ចសន្យាធានារ៉ាប់រងអាយុជីវិត ។

អ្នកទិញធានារ៉ាប់រងមានកាតព្វកិច្ចដូចខាងក្រោម ៖

១- បង់បុព្វលាភឱ្យទាន់ពេលវេលា និង យល់ព្រមលើគោលការណ៍សំខាន់ៗ នៅក្នុងកិច្ចសន្យាធានារ៉ាប់រងអាយុជីវិត ។

២- ផ្តល់នូវរបាយការណ៍ដោយលំអិត ដែលមានលក្ខណៈច្បាស់លាស់ និងគ្រប់គ្រាន់ដែលទាក់ទិនទៅនឹងកិច្ចសន្យាធានារ៉ាប់រង ដោយយោងទៅតាមតម្រូវការរបស់ក្រុមហ៊ុនធានារ៉ាប់រង ។

## ប្រការ ៦ : របាយការណ៍

ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ត្រូវទទួលខុសត្រូវក្នុងការរៀបចំ និង ផ្តល់នូវរបាយការណ៍ហិរញ្ញវត្ថុ របាយការណ៍ស្ថិតិ និងរបាយការណ៍បច្ចេកទេសអាជីវកម្ម ឱ្យស្របទៅតាមបទប្បញ្ញត្តិនៃច្បាប់ អនុក្រឹត្យ ប្រកាសនេះ និង គោលការណ៍ណែនាំរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងចេញនូវគោលការណ៍ណែនាំ ដើម្បីបង្កើតនូវតារាងមរណភាព សំរាប់ប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយប្រមូលទិន្នន័យពីប្រភពផ្លូវការផ្សេងៗ ។

**ប្រការ ៧ : របាយការណ៍សម្រាប់អ្នកត្រូវបានធានារ៉ាប់រង**

ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតត្រូវរាយការណ៍ ដោយផ្ញើឯកសារតាមប៉ុស្តិ៍ប្រៃសណីយ៍ ទៅឱ្យអ្នកត្រូវបានធានារ៉ាប់រងដោយមិនគិតថ្លៃ យ៉ាងហោចណាស់ឱ្យបានមួយដងក្នុងមួយឆ្នាំ អំពីចំណុចផ្សេងៗដូចខាងក្រោម ÷

១- លក្ខខណ្ឌចំបងនៃកិច្ចសន្យារួមមាន ឈ្មោះអ្នកត្រូវបានធានារ៉ាប់រង បុគ្គលដែលជាកម្មវត្ថុនៃការធានា អ្នកទទួលផល ការទទួលផលប្រយោជន៍ពីកិច្ចសន្យា បទប្បញ្ញត្តិ និងលក្ខខណ្ឌនៃកិច្ចសន្យា ទ្រព្យសកម្មផ្សេងៗ ដែលអាចយកមកវិញបាន បន្ទាប់ពីមានការលុបចោលកិច្ចសន្យា និង ចំណុចទាក់ទងផ្សេងៗទៀត ។

២- របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត រួមមាន តារាងតុល្យការ ចំណូលចំណាយ និង អនុបាតកម្រិតប្រាក់សាធនភាព និង អនុបាតហិរញ្ញវត្ថុផ្សេងៗទៀត ។

៣- ព័ត៌មានទំនាក់ទំនងរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ដែលរួមមាន អាសយដ្ឋាន ឈ្មោះផ្លូវ ឬ លេខផ្លូវ ទីក្រុង និង លេខទូរស័ព្ទ ដែលអាចសម្រួលដល់ការអង្កេតរបស់អ្នកទិញធានារ៉ាប់រង ព្រមទាំងព័ត៌មានដទៃផ្សេងៗទៀត ។

**ប្រការ ៨ : ករណីលើកលែង**

បើគ្មានការព្រមព្រៀងគ្នាជាមុន ដោយច្បាស់លាស់នៅក្នុងកិច្ចសន្យាធានារ៉ាប់រង ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតមិនត្រូវធ្វើសំណងនោះទេ នៅក្នុងករណីដូចខាងក្រោម ÷

១- បុគ្គលដែលជាកម្មវត្ថុនៃការធានារ៉ាប់រងត្រូវបានស្លាប់ ដោយសារការសំលាប់ខ្លួនក្នុងអំឡុងពេលពីរឆ្នាំ បន្ទាប់ពីកិច្ចសន្យាធានារ៉ាប់រងបានចូលជាធរមាន ។

២- បុគ្គលដែលជាកម្មវត្ថុនៃការធានារ៉ាប់រងត្រូវបានស្លាប់ ដោយចេតនារបស់អ្នកទិញធានារ៉ាប់រង ឬ អ្នកទទួលផលពីការធានារ៉ាប់រង ។

ក្នុងករណីដែលអ្នកទទួលផលមួយ ឬ ច្រើននាក់ ជាអ្នកបង្កហេតុឱ្យ ស្លាប់ ឬ របួសដោយចេតនាទៅលើបុគ្គលត្រូវបានធានារ៉ាប់រង ក្រុមហ៊ុនធានារ៉ាប់រងនៅតែត្រូវសងសំណងជាប្រាក់ធានារ៉ាប់រងទៅអ្នកទទួលផលដទៃផ្សេងទៀត ដោយអនុលោមទៅតាមកិច្ចសន្យាដែលបានព្រមព្រៀងគ្នា ។

## ជំពូក ៣
## ហិរញ្ញវត្ថុ និង គណនេយ្យ

### ប្រការ ៩ : ការតែងតាំងអ្នកគណនាវាយតម្លៃហានិភ័យ

ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ត្រូវប្រើប្រាស់អ្នកគណនាវាយតម្លៃហានិភ័យដែលត្រូវបានតែងតាំងឡើងដោយផ្អែកតាមស្តង់ដារជំនាញនៃអ្នកគណនាវាយតម្លៃហានិភ័យ និងដោយមានការទទួលស្គាល់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបំពេញនូវភារកិច្ចដូចខាងក្រោម ÷

១- ចុះហត្ថលេខារួមជាមួយនាយកក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ទៅលើទម្រង់ការអនុវត្តសម្រាប់ការយល់ព្រម លើផលិតផលធានារ៉ាប់រងអាយុជីវិត ។

២- បង្កើតទុនបំរុងតាមរបៀបគណិតសាស្ត្រ សម្រាប់កិច្ចសន្យាធានារ៉ាប់រង ដោយអនុលោមទៅតាមច្បាប់ និង បទប្បញ្ញត្តិជាធរមាន ។

៣- ផ្តល់ការយល់ព្រមលើការបែងចែកភាគលាភលើសប្រចាំឆ្នាំមួយចំនួន ទៅឱ្យអ្នកត្រូវបានធានារ៉ាប់រង ដោយផ្អែកលើមូលដ្ឋានត្រឹមត្រូវ និងសមហេតុផលស្របតាមច្បាប់ និង បទប្បញ្ញត្តិជាធរមាន ។

៤- វាយតម្លៃសមត្ថភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ដោយពិនិត្យទៅលើកម្រិតសាធនភាពរបស់ក្រុមហ៊ុន តាមដំណាក់កាលគណនេយ្យនីមួយៗ ។

៥- ផ្តល់របាយការណ៍ប្រចាំត្រីមាស និង ប្រចាំឆ្នាំទៅក្រុមប្រឹក្សាភិបាលក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ស្តីពីស្ថានភាពហិរញ្ញវត្ថុបច្ចុប្បន្ន និងស្ថានភាពផែនការហិរញ្ញវត្ថុនាពេលអនាគតរបស់ក្រុមហ៊ុន ។

៦- ផ្តល់របាយការណ៍ភ្លាមៗ ជាលាយល័ក្ខអក្សរទៅអគ្គនាយក និងក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត អំពីហេតុការណ៍មិនប្រក្រតីនៃស្ថានភាពហិរញ្ញវត្ថុ ដែលអាចធ្វើឱ្យខូចប្រយោជន៍ដល់ក្រុមហ៊ុន និង លើកសំណើទប់ស្កាត់ហេតុការណ៍នេះ ។

៧- ផ្ញើរបាយការណ៍ដែលបានរៀបរាប់ខាងលើ ទៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីឱ្យក្រសួងអាចចាត់វិធានការដោះស្រាយ ក្នុងករណីដែលក្រុមហ៊ុនមិនបានចាត់វិធានការឱ្យបានសមស្របក្នុងអំឡុងពេលកំណត់មួយ ដែលស្នើឡើងដោយអ្នកគណនាវាយតម្លៃហានិភ័យ ដើម្បីទប់ស្កាត់វិបត្តិហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ។

## ប្រការ ១០ : គុណវុឌ្ឍិ និង តំហែតលើអ្នកគណនាវាយតម្លៃហានិភ័យ

អ្នកគណនាវាយតម្លៃហានិភ័យដែលបានតែងតាំងឡើង ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម ÷

១- បានទទួលការបណ្តុះបណ្តាលជាអ្នកគណនាវាយតម្លៃហានិភ័យ និងមានបទពិសោធន៍ការងារយ៉ាងតិច ៥ ឆ្នាំ ក្នុងផ្នែកគណនាវាយតម្លៃហានិភ័យ នៅក្នុងវិស័យធានារ៉ាប់រងអាយុជីវិត និង ជាសមាជិករបស់សមាគមន៍អ្នកគណនាវាយតម្លៃហានិភ័យ ដែលទទួលស្គាល់ ដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

២- មានសីលធម៌វិជ្ជាជីវៈល្អ និងមិនដែលប្រព្រឹត្តិល្មើសផ្នែកវិជ្ជាជីវៈជាអ្នកគណនាវាយតម្លៃហានិភ័យ ហើយមិនដែលប្រព្រឹត្តិបទល្មើសឧក្រិដ្ឋណាមួយ ដែលទាក់ទិនទៅនឹងវិជ្ជាជីវៈរបស់ខ្លួន ។

៣- ជាបុគ្គលិករបស់ក្រុមហ៊ុនធានារ៉ាប់រង ឬ ជាបុគ្គលិករបស់ក្រុមហ៊ុនដែលផ្តល់សេវាកម្មផ្នែកគណនាវាយតម្លៃហានិភ័យ ឬ ជាអ្នកធ្វើប្រតិបត្តិការឯករាជ្យផ្នែកគណនាវាយតម្លៃហានិភ័យជាឯកជន ។

អ្នកគណនាវាយតម្លៃហានិភ័យដែលបានតែងតាំងឡើង មានវិសមភាពជាមួយមុខតំណែងដូចខាងក្រោម ÷

១- អគ្គនាយកក្រុមហ៊ុន ។

២- ប្រធានគណនេយ្យរបស់ក្រុមហ៊ុន ។

៣- សមាជិកក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ។

ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតត្រូវចុះឈ្មោះអ្នកគណនាវាយតម្លៃហានិភ័យ ដែលបានតែងតាំងរួចនៅក្នុងបញ្ជីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងរយៈពេល ១០ ថ្ងៃ (ថ្ងៃធ្វើការ) ដោយគិតចាប់ពីថ្ងៃតែងតាំង ហើយរាល់ការផ្លាស់ប្តូរនៅក្នុងការតែងតាំង អ្នកគណនាវាយតម្លៃហានិភ័យនេះ ត្រូវមានការជូនដំណឹងជាលាយល័ក្ខអក្សរដល់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៅក្នុងរយៈពេល ១០ ថ្ងៃ (ថ្ងៃធ្វើការ) ដោយគិតចាប់ពីថ្ងៃធ្វើការផ្លាស់ប្តូរនេះ ។

## ប្រការ ១១ : កម្រិតសាធនភាព

ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ត្រូវរក្សាកម្រិតសាធនភាពមិនឱ្យទាបជាងកម្រិតសាធនភាពទាបបំផុត ដែលបានកំណត់ឡើងដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## ប្រការ ១២ : ទុនបំរុង

ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតត្រូវបង្កើតទុនបំរុងផ្សេងៗដែលតម្រូវឡើងដោយ ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## ប្រការ ១៣ : កំហិតលើការវិនិយោគ

ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត អាចវិនិយោគតែទៅលើទ្រព្យសកម្មហិរញ្ញវត្ថុ និង អចលនវត្ថុតែប៉ុណ្ណោះ ដោយការណ៍នេះត្រូវធ្វើឡើងស្របទៅតាមបទប្បញ្ញត្តិរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អាចធ្វើការណែនាំដល់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ជាលាយល័ក្ខអក្សរដូចខាងក្រោម ៖

១- មិនអាចធ្វើការវិនិយោគលើទ្រព្យសកម្មហិរញ្ញវត្ថុប្រភេទណាមួយ

២- ត្រូវរៀបចំអនុវត្តការវិនិយោគជាក់ស្តែងមួយផ្នែកណាមួយ ឬ ទាំងស្រុង នៅមុនផុត រយៈកាលកំណត់ជាក់លាក់ណាមួយ ដែលអាចបន្ថែមបានដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## ប្រការ ១៤ : កំហិតលើការផ្តល់ឧបករណ៍ឥណទាន

គ្មានក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតណាមួយអាចផ្តល់ប្រាក់កំចី ឬ កម្ចីធានា ឬ ឧបករណ៍ ឥណទានផ្សេងទៀត ដើម្បីធានានូវសុវត្ថិភាពនៃភាគទុនិករបស់ខ្លួនបានឡើយ បើសិនជាគ្មាន ការអនុម័តយល់ព្រមពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជាមុន ដោយពិនិត្យទៅតាមកាលៈទេសៈ ពិសេសនៃបរិមាណទឹកប្រាក់ និង បុគ្គលដែលត្រូវផ្តល់ឱ្យនោះទេ ។

ទោះបីជាមានចែងក្នុងវាក្យខ័ណ្ឌទី១ នៃប្រការនេះក៏ដោយ ក្រុមហ៊ុនធានារ៉ាប់រង អាយុជីវិត អាចធ្វើការវិនិយោគទៅលើកម្ចីផ្នែកពាណិជ្ជកម្ម ឬសញ្ញាប័ណ្ណរដ្ឋ ទៅតាមលក្ខខណ្ឌ ដែលមានចែងនៅក្នុង ច្បាប់ អនុក្រឹត្យ ប្រកាសនេះ និង បទប្បញ្ញត្តិផ្សេងៗទៀត ។

ទោះបីជាមានចែងក្នុងវាក្យខ័ណ្ឌទី១ នៃប្រការនេះក៏ដោយ ក្រុមហ៊ុនធានារ៉ាប់រង អាយុជីវិត អាចផ្តល់ប្រាក់កម្ចីរយៈពេលខ្លី ទៅឱ្យអ្នកត្រូវបានធានារ៉ាប់រងប៉ុណ្ណោះក្នុងកម្រិត ចំនួនទឹកប្រាក់ដែលបុគ្គលនេះមានសិទ្ធិនឹងត្រូវទទួលបានពីក្រុមហ៊ុនទៅតាមករណីជាក់ស្តែង ។

**ប្រការ ១៥ : កំហិតទៅលើទ្រព្យសកម្ម**

គ្មានក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ឬដើងសាធានារ៉ាប់រងណា អាចទទួលសន្យាសង ឬទទួលខុសត្រូវលើកាតព្វកិច្ច ដោយប្រើប្រាស់ទ្រព្យសកម្ម ឬមូលបត្ររបស់ខ្លួននោះទេ លើកលែងតែមានការអនុម័តយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**ប្រការ ១៦ : ឯកសារកម្មសិទ្ធិ**

ទ្រព្យសកម្មរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតត្រូវកាន់កាប់ឡើងក្នុងប្រភេទជាក្រុមហ៊ុនសាជីវកម្ម ហើយរាល់ឯកសារដែលជាភស្តុតាងបញ្ជាក់ពីកម្មសិទ្ធិរបស់ក្រុមហ៊ុន ឬសិទ្ធិលើទ្រព្យត្រូវដាក់ឈ្មោះជាប្រភេទក្រុមហ៊ុនសាជីវកម្មផងដែរ ។

ទោះបីជាមានចែងក្នុងវាក្យខ័ណ្ឌទី១នេះក៏ដោយ នៅក្នុងការអនុវត្តរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អាចអនុញ្ញាតឱ្យមានការកាន់កាប់លើទ្រព្យសកម្មរបស់ក្រុមហ៊ុនក្នុងនាមជាអ្នកឈរឈ្មោះ តែត្រូវគោរពទៅតាមលក្ខខណ្ឌ ដែលបញ្ជាក់ឡើងដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ឯកសារដែលបរិយាយក្នុងវាក្យខ័ណ្ឌដំបូងត្រូវ ៖

១- រក្សាទុកនៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅទីកន្លែងរក្សាទុកឯកសារដែលមានសុវត្ថិភាពរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ឬនៅធនាគារ និងប្រសិនបើមានហេតុផលពិសេសណាមួយ ឯកសារនោះត្រូវបានរក្សាទុកនៅទីកន្លែងរបស់បុគ្គលផ្សេងណាមួយទៀតក្នុងនាមក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតនោះ ហើយត្រូវជូនដំណឹងទៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជាលាយលក្ខណ៍អក្សរអំពីបុគ្គលនោះ និងហេតុផលសម្រាប់ការថែរក្សានៅកន្លែងរបស់បុគ្គលនោះ និង ការប្រែប្រួលផ្សេងទៀតដែលពាក់ព័ន្ធទៅនឹងកន្លែងថែរក្សា និងហេតុផលសំរាប់ការថែរក្សា ។

២- រក្សាទុកនៅក្រៅព្រះរាជាណាចក្រកម្ពុជា នៅទីកន្លែងរក្សាទុករបស់បុគ្គលណាម្នាក់ដែលមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងស្ថិតនៅក្រោមលក្ខខណ្ឌពិសេសណាមួយ ។

៣- រក្សាទុកនៅទីកន្លែងរក្សាទុករបស់ក្រុមហ៊ុនធានារ៉ាប់រងប្រតិស្រុតិក្នុងស្រុកណាមួយ ឬនៅធនាគារក្នុងស្រុកណាមួយ នៅទីកន្លែងដែលក្រុមហ៊ុន ឬធនាគារនោះ កំពុងមានប្រតិបត្តិការអាជីវកម្មស្របច្បាប់ ដែលពាក់ព័ន្ធជាសំខាន់ដល់ទ្រព្យសកម្មនៅក្នុងទីតាំងនោះ ហើយក្រុមហ៊ុនធានារ៉ាប់រងក្នុងស្រុកនេះត្រូវជូនដំណឹងទៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាលាយលក្ខណ៍អក្សរពីអ្នកថែរក្សាឯកសារនោះ ដោយ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចតម្រូវឱ្យក្រុមហ៊ុនធានារ៉ាប់រងប្រតិស្រុតិក្នុងស្រុកផ្តល់នូវវិញ្ញាបនបត្រនៃការរក្សាទុកឯកសារ ឬ ការបញ្ជាក់ពីសវនករដែលបានធ្វើសវនកម្មរួចហើយ ។

ឯកសារដែលបានរៀបរាប់ក្នុងចំណុចទី១ នៃវាក្យខណ្ឌដំបូងបង្អស់ ឬក្នុងចំនុចទី២ ត្រូវដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់មន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងរយៈពេលណាមួយកំណត់ឡើង ដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលត្រូវជូនដំណឹងជាលាយល័ក្ខអក្សរទៅក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ឬ ទៅអ្នកថែរក្សាឯកសារ ។

## ប្រការ ១៧ : សវនកម្ម

របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ត្រូវមានការទទួលស្គាល់ ឬបានធ្វើសវនកម្មពីស្ថាប័នសវនកម្មឯករាជ្យណាមួយ ។

ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ត្រូវតែងតាំងសវនករមួយដែលមានគុណវុឌ្ឍិ ដែលការតែងតាំងនេះត្រូវមានការយល់ព្រមជាមុន ពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ហើយត្រូវផ្តល់ជារបាយការណ៍លើការតែងតាំង ឬ ការផ្លាស់ប្តូរនូវការតែងតាំងផ្សេងៗ មកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុក្នុងរយៈពេល ១០ ថ្ងៃ ( ថ្ងៃធ្វើការ ) ។

## ប្រការ ១៨ : ការវាយតម្លៃទ្រព្យសកម្ម និង ការកំណត់បំណុល

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងផ្តល់ការណែនាំពីរបៀបសម្រាប់ការវាយតម្លៃទ្រព្យសកម្ម និងទ្រព្យសម្បត្តិដទៃទៀត របស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត និង របៀបសម្រាប់ការកំណត់បំណុលផ្សេងៗរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ។

## ប្រការ ១៩ : កំហិតលើភាគលាភ

ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត អាចចែកភាគលាភទៅភាគទុនិករបស់ខ្លួន បន្ទាប់ពីក្រុមហ៊ុនបានទូទាត់រួចរាល់នូវសំណងសម្រាប់ផលធានារ៉ាប់រង និងបន្ទាប់ពីបានបង្កើតទុនបម្រុងដែលតម្រូវរួចហើយ ។

ក្នុងករណីដែលក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត លក់ផលិតផលធានារ៉ាប់រងអាយុជីវិតដែលសន្យាផ្តល់ភាគលាភទៅអ្នកត្រូវបានធានារ៉ាប់រងនោះ ភាគលាភនឹងត្រូវផ្តល់ជូនជាអាទិភាពដល់អ្នកត្រូវបានធានារ៉ាប់រងមុនទូទាត់ជូនភាគទុនិក ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងចេញនូវគោលការណ៍ណែនាំស្តីពីរបៀបនៃការបែងចែកភាគលាភទៅឱ្យភាគទុនិក ។

### ប្រការ ២០ : ការបង្ហាញនូវរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ត្រូវបង្ហាញនូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ខ្លួនជាសាធារណៈក្នុងរយៈពេល ១២០ ថ្ងៃ ដែលជារយៈពេលចុងក្រោយនៃឆ្នាំហិរញ្ញវត្ថុ ។

## ជំពូក ៤
## ប្រព្រឹត្តិកម្មក្រុមហ៊ុនស្ថិតក្នុងវិបត្តិហិរញ្ញវត្ថុ

### ប្រការ ២១ : ការជូនដំណឹងក្នុងពេលជួបវិបត្តិអសាធនភាព

ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ត្រូវកំណត់ថាស្ថិតក្នុងវិបត្តិនៃអសាធនភាព នៅពេលដែលកម្រិតសាធនភាពរបស់ក្រុមហ៊ុន ស្ថិតនៅក្រោមកម្រិតសាធនភាពអប្បបរមា ។

ក្នុងករណីដែលប្រឈមមុខនឹងវិបត្តិនៃអសាធនភាពនេះ ក្រុមហ៊ុនធានារ៉ាប់រងត្រូវជូនដំណឹងជាបន្ទាន់ទៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អំពីស្ថានភាពហិរញ្ញវត្ថុជាក់ស្តែងរបស់ខ្លួន និងហេតុផលនៃអសាធនភាពដែលកើតមាន ព្រមទាំងវិធានការសមស្របសម្រាប់ទប់ស្កាត់ ។

### ប្រការ ២២ : ការទទួលខុសត្រូវរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតក្នុងពេលជួបវិបត្តិ

ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ដែលប្រឈមមុខនឹងវិបត្តិនៃអសាធនភាព ត្រូវអនុវត្តនូវរាល់វិធានការណ៍ដូចខាងក្រោម ÷

១- បង្កើតផែនការដើម្បីស្តារកម្រិតសាធនភាព ពង្រឹងការគ្រប់គ្រង និងប្រតិបត្តិការរបស់ក្រុមហ៊ុន ដោយជូនដំណឹងទៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នូវផែនការទាំងនោះ ហើយត្រូវអនុវត្តតាមផែនការទាំងនោះ បន្ទាប់ពីបានការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

២- បំពេញតាមគោលការណ៍ណែនាំរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីស្តារកម្រិតសាធនភាពរបស់ក្រុមហ៊ុនឡើងវិញ ។

**ប្រការ ២៣ : ការទទួលខុសត្រូវរបស់ភាគទុនិកដែលមានឥទ្ធិពល**

បើសិនជាស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត អាចធានាទៅបាន ដោយភាគទុនិកជាច្រើនដែលមានឥទ្ធិពល ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អាចអនុញ្ញាត ឱ្យចូលរួមជាមួយគ្នា ឬ ដោយឡែកៗពីគ្នា ដើម្បីបង្កើនតំលៃទ្រព្យសកម្មសុទ្ធ រហូតដល់គ្រប់ចំនួនទៅតាមកំណត់នៃកម្រិតសាធនភាព ។

ភាគទុនិកដែលត្រូវបានចាត់ទុកថាជាអ្នកមានឥទ្ធិពលនៅក្នុងប្រកាសនេះ គឺភាគទុនិក ដែលកាន់កាប់ភាគទុនចាប់ពី ២០% ដោយផ្ទាល់ ឬដោយប្រយោល នៃមូលធនភាគហ៊ុនរួម ឬនៃសិទ្ធិក្នុងការបោះឆ្នោត ឬអ្នកដែលមានអំណាចសំរេចជាក់ស្តែងចំពោះករណីដែលការ កាន់កាប់ភាគហ៊ុនចែកជាចំណែកច្រើនពេកមិនប្រមូលផ្តុំនោះ ។

## ជំពូក ៥
## ការផ្ទេរអាជីវកម្មធានារ៉ាប់រងអាយុជីវិត

**ប្រការ ២៤ : ការផ្ទេរអាជីវកម្មធានារ៉ាប់រង**

គ្មានក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតណាមួយអាចផ្ទេរអាជីវកម្មរបស់ខ្លួនទាំងមូល ឬមួយផ្នែក ទៅឱ្យបុគ្គលណាម្នាក់បានទេ លើកលែងតែមានការអនុញ្ញាតជាលាយល័ក្ខអក្សរពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាមុនសិន ។

ការផ្ទេរនឹងត្រូវបានអនុញ្ញាត ក្នុងករណីមិនមានផលវិបាកអវិជ្ជមានដល់ផលប្រយោជន៍ របស់អ្នកត្រូវបានធានារ៉ាប់រង ។ មុននឹងធ្វើការផ្ទេរលក្ខខណ្ឌ និងគោលការណ៍នៃកិច្ចព្រមព្រៀងផ្ទេរ ត្រូវត្រួតពិនិត្យដោយអ្នកគណនាវាយតម្លៃហានិភ័យ ។ ការផ្ទេរអាចចាត់ទុកជាបាន ការ បន្ទាប់ពីមានការកំណត់ច្បាស់លាស់របស់អ្នកគណនាវាយតម្លៃហានិភ័យ ដែលបញ្ជាក់ថា សិទ្ធិរបស់អ្នកត្រូវបានធានារ៉ាប់រងមិនត្រូវបានប៉ះពាល់ ។

**ប្រការ ២៥ : លក្ខខណ្ឌនៃការផ្ទេរអាជីវកម្មធានារ៉ាប់រងអាយុជីវិត**

ការផ្ទេរមួយផ្នែក ឬ ទាំងមូលនៃអាជីវកម្មធានារ៉ាប់រងអាយុជីវិត រវាងក្រុមហ៊ុន ធានារ៉ាប់រងអាយុជីវិតដូចគ្នា ត្រូវបានអនុញ្ញាតទៅតាមករណីដូចខាងក្រោម ÷

១- ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតនោះ ស្ថិតក្នុងវិបត្តិនៃអសាធនភាព ។

២- អាជ្ញាប័ណ្ណធានារ៉ាប់រងអាយុជីវិតត្រូវបានដកហូត ។

៣-ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតនោះ ត្រូវបានបញ្ចូលគ្នាជាមួយក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតមួយទៀត ឬ ក្រុមហ៊ុនត្រូវបានរំលាយ ។ ក្នុងករណីនៃការបញ្ចូលគ្នាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតទាំងពីរ ត្រូវព្រមព្រៀងគ្នាលើកិច្ចសន្យានៃការផ្ទេរនោះជាមុនសិន ។

ក្នុងករណីដែលក្រុមហ៊ុនធានារ៉ាប់រងណាមួយ ស្ថិតក្នុងវិបត្តិនៃអសាធនភាព ឬត្រូវបានរំលាយ ប៉ុន្តែមិនទាន់ឈានដល់ដំណាក់កាលនៃកិច្ចព្រមព្រៀងផ្ទេរកិច្ចសន្យាធានារ៉ាប់រងទៅឱ្យក្រុមហ៊ុនធានារ៉ាប់រងមួយទៀតនោះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវចាត់តាំងក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតមួយ ដែលនឹងយល់ព្រមទទួលយកកិច្ចសន្យាធានារ៉ាប់រងបន្ត ពីក្រុមហ៊ុនដែលកំពុងស្ថិតក្នុងវិបត្តិ ។

## ប្រការ ២៦ : លក្ខខណ្ឌគម្រូសម្រាប់ការផ្ទេរអាជីវកម្មធានារ៉ាប់រងអាយុជីវិត

ការផ្ទេរអាជីវកម្មធានារ៉ាប់រងអាយុជីវិត ត្រូវបានធ្វើឡើងដោយស្របតាមលក្ខខណ្ឌដូចខាងក្រោម ÷

១- ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត នឹងត្រូវសន្មត់ថាកិច្ចសន្យាធានារ៉ាប់រងបានផ្ទេរជាមួយនឹងការផ្ទេរនូវអាជីវកម្មធានារ៉ាប់រង ។

២- សិទ្ធិ និង កាតព្វកិច្ចដែលបានព្រមព្រៀងនៅក្នុងប័ណ្ណសន្យារ៉ាប់រង គឺត្រូវបានផ្ទេរ ហើយមិនត្រូវផ្លាស់ប្តូរនោះទេ វៀតទាល់តែកិច្ចសន្យាអស់សុពលភាព និងលើកលែងតែមានការផ្លាស់ប្តូរខ្លះៗ ដែលមានការអនុញ្ញាតជាលាយល័ក្ខអក្សរពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាមុនសិន ។

៣- ការផ្ទេរត្រូវតែរួមបញ្ចូលនូវការផ្ទេរមូលនិធិ និងទុនបំរុងវិជ្ជាជីវៈទាំងអស់ ដែលជាប់ទាក់ទិនទៅនឹងកិច្ចសន្យាធានារ៉ាប់រង ដែលត្រូវបានផ្ទេរជាមួយផងដែរ ។

## ប្រការ ២៧ : នីតិវិធីសម្រាប់ការផ្ទេរប័ណ្ណសន្យារ៉ាប់រង

ការផ្ទេរអាជីវកម្មធានារ៉ាប់រងអាយុជីវិត ត្រូវបានធ្វើឡើងស្របតាមនីតិវិធីដូចខាងក្រោម ÷

១- មុនធ្វើការផ្ទេរអាជីវកម្មធានារ៉ាប់រងអាយុជីវិត ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតត្រូវដាក់ពាក្យទៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីស្នើសុំការយល់ព្រមលើការផ្ទេរអាជីវកម្មធានារ៉ាប់រងនោះ ។ ពាក្យស្នើសុំត្រូវតែបញ្ជាក់ពីមូលហេតុ និង ផែនការនៃការផ្ទេរ ព្រមទាំងបញ្ជាក់អំពីប័ណ្ណសន្យារ៉ាប់រងដែលត្រូវផ្ទេរជាមួយ ។

កិច្ចព្រមព្រៀងផ្ទេរអាចសំរេចទៅបាន បន្ទាប់ពីទទួលបានការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

២- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុអាចបដិសេធ ឬអនុញ្ញាតចំពោះផែនការដែលភ្ជាប់មកជាមួយ ដោយអាចស្នើការកែតម្រូវផ្សេងៗបាន ។

៣- ក្នុងរយៈពេល ៣០ ថ្ងៃ ដោយគិតចាប់ពីថ្ងៃទទួលបានការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈអំពីការផ្ទេរអាជីវកម្មរបស់ខ្លួន និងត្រូវជូនដំណឹងជាលាយល័ក្ខអក្សរទៅអ្នកត្រូវបានធានារ៉ាប់រងទាំងអស់ដែលពាក់ព័ន្ធ អំពីការផ្ទេរអាជីវកម្មក្រុមហ៊ុននេះ ។

## ប្រការ ២៨ : ការកែប្រែផែនការនៃការផ្ទេរអាជីវកម្ម

នៅពេលអ្នកត្រូវបានធានារ៉ាប់រង អ្នកទាមទារសំណង ឬឥណទាយកដទៃទៀត ប្តឹងជំទាស់ទៅនឹងផែនការនៃការផ្ទេរអាជីវកម្ម ដោយផ្អែកតាមប្រការ ២៧ នៃប្រកាសនេះ ទៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត អាចធ្វើការកែប្រែលក្ខខណ្ឌនៃផែនការផ្ទេរអាជីវកម្មធានារ៉ាប់រងអាយុជីវិតទៅតាមប្រការ ២៧ នេះ បន្ទាប់ពីមានការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

# ជំពូក ៦
# ការរំលាយ និង ការជម្រះបញ្ជីក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត

## ប្រការ ២៩ : ការរំលាយក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត

ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត អាចត្រូវបានរំលាយនៅក្នុងកាលៈទេសៈដូចខាងក្រោម ÷

១- ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ត្រូវបានបញ្ចូលជាមួយនិងក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតដទៃផ្សេងទៀត ។

២- ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត បានផ្ទេរប័ណ្ណសន្យារ៉ាប់រងដែលកំពុងមានសុពលភាពទាំងអស់ ទៅឱ្យក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតផ្សេងទៀត ។

៣- អាជ្ញាប័ណ្ណរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតនោះត្រូវបានដកហូត ។

៤- កត្តាផ្សេងទៀតដែលកំណត់ដោយ ច្បាប់ និង បទប្បញ្ញត្តិជាធរមាន ។

**ប្រការ ៣០ : ការអនុម័តយល់ព្រមលើការរំលាយក្រុមហ៊ុន**

ដោយអនុលោមតាម ច្បាប់ និង បទប្បញ្ញត្តិជាធរមាន ការរំលាយក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតមួយ នឹងចូលជាធរមាន បន្ទាប់ពីមានការអនុញ្ញាតពីនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

នាយករដ្ឋមន្ត្រី នឹងមិនអនុញ្ញាតឱ្យមានការរំលាយក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតណាមួយនោះទេបើបណ្ណសន្យារ៉ាប់រងអាយុជីវិតនៅមានសុពលភាពនៅឡើយ លើកលែងតែបណ្ណសន្យារ៉ាប់រងអាយុជីវិតទាំងនោះស្ថិតក្នុងលក្ខខណ្ឌដូចខាងក្រោម ÷

១- អ្នកកាន់បណ្ណសន្យារ៉ាប់រងទាំងនោះជានិយោជិត ឬជាសមាជិកនៃក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតនោះ ។

២- គ្រោះថ្នាក់ដែលមានការធានារ៉ាប់រងត្រូវបានកើតឡើងរួចហើយ កិច្ចសន្យាធានារ៉ាប់រងនឹងត្រូវអស់សុពលភាព ក្រោយការទូទាត់សំណងដែលនឹងធ្វើឡើងនៅកាលបរិច្ឆេទនៃការអនុវត្តរំលាយក្រុមហ៊ុន ។

៣- រយៈពេលកិច្ចសន្យាធានារ៉ាប់រងអាយុជីវិត ត្រូវអស់សុពលភាពនៅត្រឹមកាលបរិច្ឆេទនៃដំណើរការនៃការរំលាយក្រុមហ៊ុន ។

**ប្រការ ៣១ : ពាក្យស្នើសុំរំលាយក្រុមហ៊ុន**

ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ត្រូវរៀបចំពាក្យស្នើសុំរំលាយក្រុមហ៊ុនដោយខ្លួនឯងដោយដាក់ជូនទៅនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា តាមរយៈក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកកំណត់បែបបទនៃពាក្យស្នើសុំរំលាយក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ។

**ប្រការ ៣២ : នីតិវិធីនៃការជម្រះបញ្ជី**

ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតត្រូវបានជម្រះបញ្ជី បន្ទាប់ពីការរំលាយក្រុមហ៊ុនដែលអនុញ្ញាតដោយនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដោយយោងតាមប្រការ ៣០ នៃប្រកាសនេះ លើកលែងតែក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតនោះ បញ្ចូលគ្នាជាមួយក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតមួយផ្សេងទៀត ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកកំណត់បែបបទនៃការជម្រះបញ្ជីលើក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ។

**ប្រការ ៣៣ : ស្ថានភាពជាអាទិភាពរបស់អ្នកត្រូវបានធានារ៉ាប់រងនៅពេលជម្រះបញ្ជីក្រុមហ៊ុន**

អ្នកត្រូវបានធានារ៉ាប់រងរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត មានសិទ្ធិទាមទារសំណង មុនឥណទាយកដទៃទៀតរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ដូចការកំណត់ចែងក្នុងច្បាប់ និង បទប្បញ្ញត្តិផ្សេងៗដែលមានជាធរមាន ។

## ជំពូក ៧
## ការលក់ប័ណ្ណសន្យារ៉ាប់រងអាយុជីវិត

**ប្រការ ៣៤ : បណ្តាញលក់ប័ណ្ណសន្យារ៉ាប់រងអាយុជីវិត**

ប័ណ្ណសន្យារ៉ាប់រងអាយុជីវិត អាចត្រូវបានលក់តាមរយៈនិយោជិតរបស់ក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង និង ជើងសាធានារ៉ាប់រងអាយុជីវិត ។

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលបានចែងនៅក្នុងអនុក្រឹត្យស្តីពីការធានារ៉ាប់រង ចំពោះភ្នាក់ងារធានារ៉ាប់រង និង ជើងសាធានារ៉ាប់រង នឹងត្រូវអនុវត្តដូចគ្នាចំពោះបុគ្គលដែលប្រតិបត្តិអាជីវកម្មធានារ៉ាប់រងអាយុជីវិត ។

**ប្រការ ៣៥ : អាជ្ញាប័ណ្ណភ្នាក់ងារធានារ៉ាប់រង និង ជើងសាធានារ៉ាប់រង**

ភ្នាក់ងារធានារ៉ាប់រងអាយុជីវិត និង ជើងសាធានារ៉ាប់រងអាយុជីវិតទាំងអស់ ត្រូវមានអាជ្ញាប័ណ្ណដែលផ្តល់ឱ្យដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីធ្វើប្រតិបត្តិការអាជីវកម្មធានារ៉ាប់រងអាយុជីវិត ។ ផ្នែកទី ២ នៃជំពូក ៤ នៃអនុក្រឹត្យស្តីពីការធានារ៉ាប់រង គឺត្រូវអនុវត្តទៅលើភ្នាក់ងារធានារ៉ាប់រង និង ជើងសាធានារ៉ាប់រងដែលធ្វើប្រតិបត្តិការអាជីវកម្មធានារ៉ាប់រងអាយុជីវិត ។

**ប្រការ ៣៦: ការចុះឈ្មោះនិយោជិតរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត**

និយោជិតរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតដែលជាអ្នកលក់ប័ណ្ណសន្យារ៉ាប់រងអាយុជីវិត ត្រូវតែមានចំណេះដឹងគ្រប់គ្រាន់អំពីហានិភ័យទាំងឡាយ និងអត្ថប្រយោជន៍នៃការធានារ៉ាប់រងអាយុជីវិតនេះ ។

គ្រប់និយោជិតទាំងអស់របស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ដែលអាចលក់ ឬទទួលលក់ប័ណ្ណសន្យារ៉ាប់រងអាយុជីវិតទៅឱ្យអតិថិជន ត្រូវចុះឈ្មោះក្នុងបញ្ជីនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**ប្រការ ៣៧ : ការជ្រើសរើសវិទ្យាស្ថានបណ្តុះបណ្តាល**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងជ្រើសរើសនូវវិទ្យាស្ថានណាមួយ ដែលអាចផ្តល់កម្មវិធីបណ្តុះបណ្តាលជំនាញលក់ រួមមាន ជំនាញភ្នាក់ងារធានារ៉ាប់រង ជើងសាធានារ៉ាប់រង និង និយោជិតរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ។ វិទ្យាស្ថានដែលជ្រើសរើសយកត្រូវរៀបចំការប្រលង ដើម្បីផ្តល់វិញ្ញាបនបត្រដែលមានគុណភាពដល់ភ្នាក់ងារធានារ៉ាប់រង ជើងសាធានារ៉ាប់រង និង និយោជិតក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ។

## ជំពូក ៨
## ការប្រព្រឹត្តិល្មើសនៅក្នុងអាជីវកម្មធានារ៉ាប់រង

**ប្រការ ៣៨ : ការប្រព្រឹត្តិល្មើស**

ការប្រព្រឹត្តិល្មើសនៅក្នុងអាជីវកម្មធានារ៉ាប់រងអាចមានករណីដូចខាងក្រោម ÷

១- ការប្រតិបត្តិអាជីវកម្មធានារ៉ាប់រង ដោយបុគ្គលណាមួយដែលគ្មានអាជ្ញាប័ណ្ណធានារ៉ាប់រងអាយុជីវិត ។

២- ការប្រព្រឹត្តិល្មើសនឹងបទប្បញ្ញត្តិដែលមានកំណត់ក្នុងអាជ្ញាប័ណ្ណ និង បទបញ្ជាផ្សេងៗ សំរាប់ការអង្កេត និង ការត្រួតពិនិត្យរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬ ការធ្វេសប្រហែសផ្សេងៗ ។

៣- ការបង្ខំដើម្បីឱ្យមានការចុះហត្ថលេខាលើកិច្ចសន្យាធានារ៉ាប់រងអាយុជីវិត ។

៤- សកម្មភាពផ្សេងទៀតដែលល្មើសផ្ទុយនឹងច្បាប់ អនុក្រឹត្យស្តីពីការធានារ៉ាប់រង និង បទប្បញ្ញត្តិនេះ ។

**ប្រការ ៣៩ : ទោសប្បញ្ញត្តិ**

បុគ្គលណាដែលប្រព្រឹត្តផ្ទុយនឹងបទប្បញ្ញត្តិនៃប្រកាសនេះ នឹងត្រូវទទួលការផាកពិន័យជាប្រាក់ចំនួនពី ១០ (ដប់) លានរៀល ទៅ ២០ (ម្ភៃ) លានរៀល ដោយបង់ចូលរតនាគារជាតិតាមដីកាអមរបស់នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ និង ទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ ៤០ :**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៩១ :**

ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៨

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

**ចម្លងជូន :**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ឯកសារ-កាលប្បវត្តិ